CPEHN
California Pan-Ethnic Health Network

APIAHF
ASIAN & PACIFIC ISLANDER
AMERICAN HEALTH FORUM

# ស្តីអំពីការកែប្រែផ្នែកសុខភាព ដែលផ្តល់ផលប្រយោជន៍ដល់រូបអ្នក ក្រុមគ្រួសារអាស៊ី និងកោះប៉ាស៊ីហ្វិក នៅរដ្ឋកាលីហ្វ័រនីញ៉ា

ក្រុមគ្រួសារអាស៊ី ជនកោះប៉ាស៊ីហ្វិក នឹងទទួលផលប្រយោជន៍ពីច្បាប់សុខភាពថ្មី។ នេះជាសេចក្តីពិត ទោះជាអ្នកពុំមានការធានារ៉ាប់រង មានម៉េឌីខាល់ Medi-Cal ឬម៉េឌីឃែរ Medicare, ឬការធានារ៉ាប់រងឯកជន។

បើសិនជាអ្នកពុំមានការធានារ៉ាប់រងសុខភាព ឬវាពុំគ្រប់គ្រាន់ទៅតាមសេចក្តីត្រូវការរបស់អ្នក ជំនួយនឹងមកដល់ក្នុងពេល ឆាប់ៗនេះ។ បើសិនអ្នកជាជនជរា អ្នកនឹងទទួលផលប្រយោជន៍ ពីផ្នែកថ្នាំពេទ្យចុះថ្លៃ និងផ្នែកបង្កាសុខភាពដោយឥតគិតថ្លៃ។ បើអ្នកមានការធានារ៉ាប់រងផ្នែកសុខភាពអ្នកអាចនៅតែទទួលការពិនិត្យសុខភាពពីវេជ្ជបណ្ឌិតដដែល ដោយគ្មានបារម្ភថាផ្នែកធានារ៉ាប់រងសុខភាព នឹងឈប់ទទួលអ្នក ឬកំរិតការធានារ៉ាប់រងនៅពេលដែលអ្នកឈឺ និងត្រូវការ។ ទោះជាអ្នកមានការធានារ៉ាប់រង ឬគ្មាន ច្បាប់សុខភាពថ្មីក៏នឹងជួយគាំទ្រជីវិតពោរពេញទៅដោយសុខភាពបរិបូរណ៍ តាមរយៈកម្មវិធីសុខមាលភាពនៅកន្លែងធ្វើការ និងប្រាក់ជំនួយសហគមន៍ ដើម្បីបង្កើនភាពងាយស្រួលទទួលម្ហូបអាហារជីវជាតិល្អ និងសកម្មភាពកាយវប្បកម្ម។

- **បើអ្នកត្រូវការ ការធានារ៉ាប់រង - ជម្រើសធានារ៉ាប់រងតម្លៃសមរម្យ មានកាន់តែច្រើនទៀត**
- **បើអ្នកមានម៉េឌីខាល់ Medi-Cal ឬម៉េឌីឃែរ Medicare – ភាពងាយស្រួលក្នុងការទទួលសេវានិងសេវាប្រកបដោយគុណភាពប្រសើរ មានកាន់តែច្រើនឡើង**
- **បើអ្នកមានការធានារ៉ាប់រងឯកជន – អ្នកគ្មានបារម្ភ និងមានការធានារ៉ាប់រងតម្លៃសមរម្យ**

**បើអ្នកត្រូវការ ការធានារ៉ាប់រង- ជម្រើសទៅលើការធានារ៉ាប់រងមានកាន់តែច្រើនឡើង**

ដោយផ្តល់ជម្រើសកាន់តែច្រើនឡើងទៅលើការធានារ៉ាប់រងតម្លៃសមរម្យ ច្បាប់សុខភាពថ្មី នឹងជួយក្រុមគ្រួសារអាស៊ី និងកោះប៉ាស៊ីហ្វិកចំនួន ៦០% ដែលបច្ចុប្បន្ននេះគ្មានការធានារ៉ាប់រង អោយមានការធានារ៉ាប់រង។ *ជនអន្តោប្រវេសន្តពេញច្បាប់ នឹងមានសិទ្ធិទទួលយោងតាមមាត្រាទាំងអស់ដូចខាងក្រោមនេះ។*

**ចំពោះជនពេញវ័យក្មេង- អ្នកអាចនៅក្នុងគំរោងសុខភាពក្រុមគ្រួសាររហូតដល់ទៅអាយុ២៦ឆ្នាំ :**

ចាប់ផ្តើមឡើងភ្លាមនេះជនពេញវ័យក្មេង នឹងអាចនៅក្នុងគំរោងសុខភាពរបស់ឪពុកម្តាយរបស់គេរហូតដល់ទៅអាយុ២៦ឆ្នាំ។ វិធីនេះនឹងជួយជនពេញវ័យក្មេងអាស៊ី និងកោះប៉ាស៊ីហ្វិក១នាក់ ក្នុងចំណោម៤នាក់ដែលគ្មានការធានារ៉ាប់រង នៅកំឡុងឆ្នាំ២០០៧។

- **សេវាបន្ថែមផ្នែកម៉េឌីខាល់ Medi-Cal ជួយដល់រូបអ្នក និងក្រុមគ្រួសាររបស់អ្នក :**
  ចាប់ផ្តើមឡើងនៅឆ្នាំ២០១៤ បើអ្នកមានប្រាក់ចំណូលតិចជាង $14,431 ជាជនពេញវ័យម្នាក់ ឬ$29,367ហើយមានសមាជិកគ្រួសារបួននាក់ អ្នកនឹងមានសិទ្ធិទទួលម៉េឌីខាល់ Medi-Cal ។ សេវាបន្ថែមនេះ នឹងជួយផ្តល់ការធានារ៉ាប់រងដល់ជនជាតិអាស៊ី និងកោះប៉ាស៊ីហ្វិកជាង 140,000 នៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា។ សេវាម៉េឌីខាល់ Medi-Cal ផ្នែកថែទាំស្ត្រីមានផ្ទៃពោះ និងផ្នែកអាសន្ន នៅតែមានសំរាប់ជនគ្រប់រូបដែលមានប្រាក់ចំណូលតិច ដោយគ្មានគិតពីស្ថានភាពអន្តោប្រវេសន្តឡើយ។



- **សេវាហ៊ុនធានារ៉ាប់រងសុខភាព នឹងផ្តល់ការធានារ៉ាប់រងឯកជនតម្លៃសមរម្យ:** ក៏នឹងចាប់ផ្តើមឡើងនៅឆ្នាំ 2014 បើអ្នកមានប្រាក់ចំណូលតិចជាង$43,400 ជាជនពេញវ័យម្នាក់ ឬមានប្រាក់ចំណូល$88,200ហើយមានសមាជិកគ្រួសារបួននាក់ អ្នកនឹងអាចទិញការធានារ៉ាប់រងតម្លៃសមរម្យពីសេវាហ៊ុនធានារ៉ាប់រងសុខភាព។ ប្រាក់បង់បន្ថែមពុំលើសពី10%នៃប្រាក់ចំណូលរបស់អ្នកឡើយ-រដ្ឋាភិបាលនឹងបង់ថ្លៃដែលនៅសល់ទាំងប៉ុន្មាន។ *ជនមានសញ្ជាតិ កូនរបស់ជនអន្តោប្រវេសន្តគ្មានពេញច្បាប់ តែអាចបង្ហាញភស្តុតាងសិទ្ធិរស់នៅអចិន្ត្រៃយ៍អាចទទួលការធានារ៉ាប់រង តាមរយៈសេវាហ៊ុនធានារ៉ាប់រងសុខភាព។ ជនអន្តោប្រវេសន្តគ្មានពេញច្បាប់ពុំអាចទទួលការធានារ៉ាប់រងពីសេវាហ៊ុនធានារ៉ាប់រងសុខភាពហើយទទួលការលើកលែងពីការតម្រូវអោយមានការធានារ៉ាប់រង។*
- **និយោកជន (ម្ចាស់)ពាណិជ្ជកម្មតូចៗ នឹងទទួលជំនួយក្នុងការផ្តល់ការធានារ៉ាប់រងដល់អ្នក :** ពាណិជ្ជកម្មតូចៗ ចំនួន500,000 នៅរដ្ឋកាលីហ្វ័រនីញ៉ា នឹងទទួលជំនួយផ្នែកពន្ធដារ ដើម្បីជួយផ្តល់ការធានារ៉ាប់រងដលបុគ្គលិក។

## បើអ្នកមានម៉េឌីខាល់ Medi-Cal ឬម៉េឌីខាល់Medicare –បង្កើនភាពងាយស្រួល និងគុណភាពសេវាប្រសើរឡើង

- **ជួយជនជរា ដែលទទួលម៉េឌីឃែ Medicare:** ច្បាប់ថ្មីបិទ ចំណុចខ្វះខាត ” នៅក្នុងផ្នែកម៉េឌីឃែ Medicare ជួយជនអាស៊ី និងកោះប៉ាស៊ីហ្វិករាប់ពាន់អ្នក ដោយចេញថ្លៃថ្នាំពេទ្យ ចាប់ផ្តើមឡើងនៅឆ្នាំ 2011។ ហើយនឹងផ្តល់សេវាងបង្ការោគដោយឥតគិតថ្លៃ។
- **មានវេជ្ជបណ្ឌិត និងវេជ្ជបណ្ឌិតឯកទេសផ្តល់សេវាជូនអ្នកកាន់តែច្រើនឡើង :** ថ្លៃសេវារបស់វេជ្ជបណ្ឌិតមានចំនួនច្រើនឡើងនៅក្នុងច្បាប់ថ្មី។ មានន័យថាមានវេជ្ជបណ្ឌិត និងវេជ្ជបណ្ឌិតឯកទេសកាន់តែច្រើនឡើងសំរាប់បំរើអ្នក។
- **ការរង់ចាំទទួលសេវាមានរយៈពេលខ្លីជាងមុន :** មានវេជ្ជបណ្ឌិត និងសេវាកាន់ច្រើនឡើង នឹងកាត់បន្ថយរយៈពេលរង់ចាំ។
- **គាំទ្របណ្តាញរបស់យើង :** ច្បាប់នឹងនាំមកថវិកាប្រហែលជាចំនួន 1.4 កោដិដុល្លារ ដើម្បីជួយមណ្ឌលសុខភាពសហគមន៍ ដែលបំរើជនជាតិអាស៊ី និងកោះប៉ាស៊ីហ្វិករាប់ពាន់នាក់។
- **បើអ្នកមានការធានារ៉ាប់រងឯកជន : គ្មានបារម្ភ និងមានការធានារ៉ាប់រងតម្លៃសមរម្យ**

ចំពោះជនជាតិអាស៊ី និងកោះប៉ាស៊ីហ្វិកចំនួន 2.7 លាននាក់ នៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា ដែលមានការធានារ៉ាប់រងឯកជន ការធានារ៉ាប់រងសុខភាពរបស់អ្នកនឹងមានស្ថេរភាព ថ្លៃសមរម្យ និងជួយអ្នកអោយមានសុខភាពល្អ។

- **គ្មានកំរិតទៅលើផ្នែកថែទាំប្រចាំជីវិត :** ចាប់ផ្តើមឡើងនៅរដូវស្លឹកឈើជ្រុះនេះ ច្បាប់ថ្មីហាមមិនអោយផ្នែកធានារ៉ាប់រងសុខភាពដាក់កំរិតទៅលើការបង់ថ្លៃសេវាឡើយ។ ពុំមានជនណាម្នាក់បារម្ភថា គេនឹងអស់ផ្ទះ ឬអស់ទ្រព្យនៅពេលដែលរូបគេ ឬជនដែលគេស្រឡាញ់ឈឺថ្កាត់។
- **ផ្តល់អារម្មណ៍ក្សេមក្សានដល់អ្នក:** ផ្នែកធានារ៉ាប់រងសុខភាព ពុំអាចបដិសេធការធានារ៉ាប់រងសុខភាព ទៅលើស្ថានភាពសុខដែលមានពីមុនមក ឬបញ្ឈប់ការធានារ៉ាប់រងនៅពេលដែលអ្នកឈឺឡើយ។ មាត្រានេះចែងឡើងសំរាប់កុមារ ចាប់ផ្តើមឡើនៅរដូវស្លឹកឈើជ្រុះនេះ និងសំរាប់ជនពេញវ័យគ្រប់រូបនៅឆ្នាំ 2014។
- **ចាត់ភាពបង្កាទុកមុនគេ :** គំរោងធានាសុខភាពថ្មីទាំងអស់ នឹងផ្តល់ការធានារ៉ាប់រងទៅលើសេវាបង្ការោគ-ដូចជាការពិនិត្យរករោគ និងធ្វើតេស្ត -ដោយឥតគិតថ្លៃ ចាប់ផ្តើមឡើងនៅរដូវស្លឹកឈើជ្រុះ។

## បើអ្នកជាជនអន្តោប្រវេសន៍ : ផលប្រយោជន៍មាន

ផលប្រយោជន៍ទាំងអស់នៃការកែប្រែសុខភាពនឹងមានសំរាប់ជនអន្តោប្រវេសន្តពេញច្បាប់ ហើយជនទាំងនោះអាចទទួលសេវាសុខភាពបន្ថែមសហគមន៍។

- **ជនអន្តោប្រវេសន្តពេញច្បាប់នៅតែអាចទទួលម៉េឌីខាល់ Medi-Cal:** ជនអន្តោប្រវេសន្តពេញច្បាប់នៅតែមានសិទ្ធិទទួលម៉េឌីខាល់Medi-Cal ដោយគ្មានកំរិតរង់ចាំ។
- **ជនអន្តោប្រវេសន្តពេញច្បាប់មានសិទ្ធិទទួលជំនួយសេវាហ៊ុន :** ជនអន្តោប្រវេសន្តពេញច្បាប់ នឹងមានសិទ្ធិ ទទួលកំរៃពន្ធដារ និងជំនួយដើម្បីទិញសេវាហ៊ុនធានារ៉ាប់រងសុខភាព ដោយគ្មានកំរិតរង់ចាំ។
- **សេវាហ៊ុនធានារ៉ាប់រងសុខភាពគ្មានសំរាប់ជនអន្តោប្រវេសន្តគ្មានច្បាប់ :** ជនអន្តោប្រវេសន្តគ្មានច្បាប់ ពុំអាចទិញសេវាហ៊ុនធានារ៉ាប់រងសុខភាព ហើយលើកលែងពីការតម្រូវអោយមានការធានារ៉ាប់រង។